# កិច្ចព្រមព្រៀង

## រវាង
## រដ្ឋាភិបាលនៃប្រទេសអូស្ត្រាលី
## និង
## រាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
## ស្តីពី
## ការបញ្ជូនទណ្ឌិត

រដ្ឋាភិបាលនៃប្រទេសអូស្ត្រាលី និងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា តទៅហៅកាត់ថា "**ភាគី**"

- បានឃើញច្បាប់ និងលិខិតបទដ្ឋានជាធរមាននានា ដែលទាក់ទងនឹងការអនុវត្តច្បាប់របស់ភាគីទាំងពីរ និងក្នុងបំណងពង្រឹងកិច្ចខិតខំប្រឹងប្រែងសហការក្នុងការអនុវត្តច្បាប់ និងការគ្រប់គ្រងប្រព័ន្ធយុត្តិធម៌
- ដោយមានបំណងសហការក្នុងការអនុវត្តទោសព្រហ្មទណ្ឌ និង
- ដោយមានបំណងសហការក្នុងការបញ្ជូនទណ្ឌិត ដើម្បីសម្រួលការធ្វើសមាហរណកម្មពួកគេចូលទៅក្នុងសង្គមវិញដោយជោគជ័យ

បានព្រមព្រៀងគ្នាដូចតទៅ :

### មាត្រា ១: និយមន័យ

តាមគោលបំណងនៃកិច្ចព្រមព្រៀងនេះ :

ក- ពាក្យថា "**ភាគីបញ្ជូន**" សំដៅដល់ភាគីដែលបញ្ជូនទណ្ឌិតចេញពីទឹកដីដែលស្ថិតនៅក្រោមយុត្តាធិការរបស់ខ្លួន ។

ខ- ពាក្យថា "**ភាគីទទួល**" សំដៅដល់ភាគីដែលទទួលយកទណ្ឌិត ។

គ- ពាក្យថា "**ទណ្ឌិត**" សំដៅដល់ជនដែលត្រូវជាប់ឃុំឃាំងនៅក្នុងពន្ធនាគារ មន្ទីរពេទ្យ ឬ កន្លែងដ៏ទៃផ្សេងទៀត នៅក្នុងដែនដីនៃភាគីបញ្ជូន ដើម្បីទទួលទោស ហើយក៏សំដៅផងដែរដល់ជនល្មើសដែលត្រូវបានដោះលែងដោយមានលក្ខខណ្ឌ ។

ឃ- ពាក្យថា "**ទោស**" សំដៅដល់ការដាក់ទណ្ឌកម្ម ឬវិធានការដកហូតសិទ្ធិសេរីភាពណាមួយដែលសម្រេចដោយតុលាការ សម្រាប់រយៈពេលមួយមានកំណត់ ឬគ្មានកំណត់ នៅក្នុងកំឡុងពេលអនុវត្តយុត្តាធិការព្រហ្មទណ្ឌរបស់ខ្លួន ។

ង- ពាក្យថា "**ដែនដី** " សំដៅដល់

១- សម្រាប់ព្រះរាជាណាចក្រកម្ពុជា គឺដែនដីទាំងអស់ដែលស្ថិតក្នុងយុត្តាធិការរបស់ព្រះរាជាណាចក្រកម្ពុជា និង

២- សម្រាប់ប្រទេសអូស្ត្រាលី គឺជាបណ្តារដ្ឋ និងដែនដីនានារបស់ប្រទេសអូស្ត្រាលី ដោយរួមបញ្ចូលទាំងដែនដីនានានៅក្រៅប្រទេសអូស្ត្រាលីផងដែរ ។

ច- ពាក្យថា "**ទំនាក់ទំនងសហគមន៍** " សំដៅដល់ :

១- ភ្លាមៗមុនពេលត្រូវបានកាត់ទោសអោយជាប់ពន្ធនាគារនៅក្នុងដែនដីនៃភាគីបញ្ជូន ទណ្ឌិតមានលំនៅដ្ឋានចម្បងនៅក្នុងដែនដីនៃភាគីទទួល ឬ

២- ឪពុក-ម្តាយ ជីដូន-ជីតា ឬកូនរបស់ទណ្ឌិត មានលំនៅដ្ឋានចម្បងមួយនៅក្នុងដែនដីនៃភាគីទទួល ឬ

៣- ទណ្ឌិតរៀបអាពាហ៍ពិពាហ៍ ឬ មានទំនាក់ទំនងជាក់ស្តែងជាមួយជនណាម្នាក់ដែលមានលំនៅដ្ឋានចម្បងនៅក្នុងដែនដីនៃភាគីទទួល ឬ

៤- ទណ្ឌិតមានទំនាក់ទំនងជិតស្និទ្ធបន្តតដាច់ជាមួយជនណាម្នាក់ ដែលមានលំនៅដ្ឋានចម្បងនៅក្នុងដែនដីនៃភាគីទទួល ដូចជាការប្រាស្រ័យទាក់ទងញឹកញាប់ជាលក្ខណៈបុគ្គល និងការយកចិត្តទុកដាក់ជាលក្ខណៈបុគ្គលចំពោះសុខុមាលភាពរបស់ជនម្នាក់ផ្សេងទៀតជាដើម ។

## មាត្រា ២: គោលបំណងនៃកិច្ចព្រមព្រៀង

១- ភាគីទាំងពីរត្រូវសហការអោយបានទូលំទូលាយបំផុតក្នុងការបញ្ជូនទណ្ឌិត ស្របតាមបទប្បញ្ញត្តិនានានៃកិច្ចព្រមព្រៀងនេះ ។

២- ទណ្ឌិតអាចត្រូវបានបញ្ជូនចេញពីដែនដីរបស់ភាគីបញ្ជូន ទៅកាន់ដែនដីរបស់ភាគីទទួល ស្របទៅតាមបទប្បញ្ញត្តិនានានៃកិច្ចព្រមព្រៀងនេះ ដើម្បីទទួលទោសដែលបានកំណត់លើខ្លួន ។

## មាត្រា ៣: អាជ្ញាធរកណ្តាល

១- អាជ្ញាធរកណ្តាលរបស់ភាគីទាំងពីរត្រូវរៀបចំចាត់ចែងពាក្យស្នើសុំបញ្ជូន ស្របទៅតាមបទប្បញ្ញត្តិនានានៃកិច្ចព្រមព្រៀងនេះ ។

២- អាជ្ញាធរកណ្តាលរបស់ព្រះរាជាណាចក្រកម្ពុជា គឺក្រសួងយុត្តិធម៌ ។ អាជ្ញាធរកណ្តាលរបស់ប្រទេសអូស្ត្រាលី គឺក្រសួងអគ្គរដ្ឋអាជ្ញារបស់រដ្ឋាភិបាលអូស្ត្រាលី ។ ភាគីណាមួយក្នុងចំណោមភាគីទាំងពីរ អាចផ្លាស់ប្តូរអាជ្ញាធរកណ្តាលរបស់ខ្លួនបាន ដែលនៅក្នុងករណីនោះ ភាគីផ្លាស់ប្តូរត្រូវជូនដំណឹងទៅភាគីម្ខាងទៀតអំពីការផ្លាស់ប្តូរនេះ ។

៣- អាជ្ញាធរកណ្តាលនៃភាគីទាំងពីរអាចទំនាក់ទំនងគ្នាដោយផ្ទាល់ តាមគោលបំណងនៃកិច្ចព្រមព្រៀងនេះ ។

## មាត្រា ៤: លក្ខខណ្ឌនៃការបញ្ជូន

តាមកិច្ចព្រមព្រៀងនេះ ការបញ្ជូនទណ្ឌិតអាចប្រព្រឹត្តទៅបាន តែក្នុងករណីដូចខាងក្រោម :

ក- អំពើ ឬការគេចវេសមិនបានបំពេញទាំងឡាយដែលនាំអោយមានការដាក់ទោស គឺជាធាតុផ្សំសំខាន់នៃបទល្មើសព្រហ្មទណ្ឌមួយស្របតាមច្បាប់នៃភាគីទទួល ឬអាចជាធាតុផ្សំសំខាន់នៃបទល្មើសព្រហ្មទណ្ឌ ប្រសិនបើបានប្រព្រឹត្តឡើងនៅក្នុងយុត្តាធិការនៃភាគីទទួល ។ លក្ខខណ្ឌនេះអាចលើកលែងបានក្នុងករណីពិសេសមួយ ប្រសិនបើភាគីទាំងពីរឯកភាព និងនៅក្នុងកំរិតមួយដែលច្បាប់របស់ភាគីទទួលអនុញ្ញាត ។

ខ- ក្នុងករណីដែលព្រះរាជាណាចក្រកម្ពុជាជាភាគីទទួល ទណ្ឌិតគឺជាពលរដ្ឋកម្ពុជា ។

គ- ក្នុងករណីដែលប្រទេសអូស្ត្រាលីជាភាគីទទួល ទណ្ឌិតគឺជា:

១- ពលរដ្ឋអូស្ត្រាលី ឬ

២- ជនដែលត្រូវបានអនុញ្ញាតអោយធ្វើដំណើរចូលទៅក្នុង និងស្នាក់នៅក្នុងប្រទេសអូស្ត្រាលី ដោយគ្មានកំណត់រយៈពេល ស្របតាមច្បាប់អូស្ត្រាលី និងមានទំនាក់ទំនងសហគមន៍ជាមួយរដ្ឋ ឬដែនដីណាមួយរបស់ប្រទេសអូស្ត្រាលី ។

ឃ- ជនល្មើសមិនត្រូវបានផ្តន្ទាទោសដោយច្បាប់កម្ពុជា ដោយសារបានប្រព្រឹត្តបទល្មើសណាមួយដូចខាងក្រោមនេះទេ :

១- បទល្មើសប្រឆាំងនឹងសន្តិសុខផ្ទៃក្នុង ឬក្រៅប្រទេសរបស់រដ្ឋ

២- បទល្មើសប្រឆាំងនឹងព្រះមហាក្សត្រ ឬសមាជិកញាតិវង្សានុវង្ស

៣- បទល្មើសប្រឆាំងនឹងច្បាប់ការពារបិតិកភ័ណ្ឌសិល្បៈជាតិខ្មែរ ។

ង- នៅពេលដែលមានសំណើសុំបញ្ជូន ទណ្ឌិតនៅសល់ពេលដែលត្រូវទទួលទោសយ៉ាងតិច ១ ឆ្នាំ ទៀត ។ លក្ខខណ្ឌនេះអាចលើកលែងបាន តាមរយៈការព្រមព្រៀងរវាងភាគីទាំងពីរ ។

ច- សាលក្រមកាត់ទោស គឺជាសេចក្តីសម្រេចចុងក្រោយ ហើយមិនមាននីតិវិធីតាមផ្លូវច្បាប់ផ្សេងទៀត ទាក់ទងទៅនឹងបទល្មើសនោះ ឬបទល្មើសផ្សេងទៀត ដែលរង់ចាំការសម្រេចនៅក្នុងដែនដីរបស់ភាគីបញ្ជូនទេ ។

ឆ- ភាគីបញ្ជូន និងភាគីទទួល ព្រមទាំងទណ្ឌិត ត្រូវព្រមព្រៀងគ្នាលើការបញ្ជូន ។ ក្នុងករណីដែលទណ្ឌិតមិនអាចផ្តល់ការយល់ព្រមបាន ដោយផ្អែកតាមច្បាប់នៃភាគីបញ្ជូន ការយល់ព្រមអាចត្រូវផ្តល់ដោយបុគ្គលម្នាក់ដែលបានទទួលសិទ្ធិក្នុងការតំណាងអោយទណ្ឌិត ។

ជ- ទណ្ឌិតបានទទួលព័ត៌មានគ្រប់គ្រាន់ដែលផ្តល់ដោយភាគីទទួល អំពីរាល់ការចំណាយពាក់ព័ន្ធនឹងការបញ្ជូន ដែលភាគីទទួលអាចតម្រូវអោយទណ្ឌិតបង់សង ស្របទៅតាមកថាខ័ណ្ឌទី ៣ នៃមាត្រា ១២ ។

## មាត្រា ៥: នីតិវិធីសម្រាប់ការបញ្ជូន

១- ភាគីទាំងពីរត្រូវខិតខំផ្តល់ដំណឹងដល់ទណ្ឌិត អំពីខ្លឹមសារនៃកិច្ចព្រមព្រៀងនេះ ។

២-

ក-	ប្រសិនបើទណ្ឌិតមានបំណងចង់អោយមានការបញ្ជូន ទណ្ឌិតអាចបង្ហាញបំណងនេះចំពោះភាគីបញ្ជូន ឬភាគីទទួល ដែលភាគីនីមួយៗ ត្រូវជូនដំណឹងទៅវិញទៅមកជាលាយលក្ខណ៍អក្សរ ។

ខ-	សំណើសុំបញ្ជូនអាចត្រូវធ្វើឡើងដោយភាគីទទួល ទៅកាន់ភាគីបញ្ជូន ។

គ-	សំណើសុំបញ្ជូនត្រូវធ្វើជាលាយលក្ខណ៍អក្សរ និងត្រូវបញ្ជូលនូវព័ត៌មានមានដូចខាងក្រោម :

១-	នាម និងគោត្តនាម កាលបរិច្ឆេទ និងទីកន្លែងកំណើតរបស់ទណ្ឌិត

២-	លិខិតបញ្ជាក់អំពីសញ្ជាតិ ជនជាតិ ឬសិទ្ធិស្នាក់នៅរបស់ទណ្ឌិត និង

៣-	ទីតាំងរបស់ទណ្ឌិត និងអាសយដ្ឋានបច្ចុប្បន្ន។

៣-	នៅពេលមានការស្នើសុំអោយបញ្ជូន ភាគីបញ្ជូនត្រូវតែផ្តល់ជូនភាគីទទួលនូវព័ត៌មានដូចខាងក្រោម :

ក-	សេចក្តីថ្លែងការណ៍មួយរៀបរាប់ពីអង្គហេតុដែលជាមូលដ្ឋាននៃការវិនិច្ឆ័យទោស និងការដាក់ទោស និងសេចក្តីថ្លែងការណ៍មួយស្តីពីច្បាប់ពាក់ព័ន្ធដែលចែងពីបទល្មើសនោះ ។

ខ-	កាលបរិច្ឆេទបញ្ចប់ការទទួលទោស ប្រសិនបើមាន និងរយៈពេលដែលទណ្ឌិតបានទទួលទោសរួច ព្រមទាំងការបន្ធូរបន្ថយទោសនានាដែលទណ្ឌិតត្រូវទទួលបាន ដោយផ្អែកលើការងារដែលបានបំពេញ ដូចជា បានកែប្រែអត្តចរិតល្អ ការឃុំឃាំងមុនពេលវិនិច្ឆ័យទោស ឬមូលហេតុដទៃទៀត។

គ-	ឯកសារចម្លងមួយច្បាប់នៃលិខិតបញ្ជាក់ ឬកំណត់ហេតុស្តីពីការវិនិច្ឆ័យទោស និងការដាក់ទោស ហើយប្រសិនបើមាន ឯកសារចម្លងនៃសាលក្រមទាំងឡាយ ព្រមទាំងកំណត់សំគាល់អំពីការដាក់ទោស ។

ឃ-	ព័ត៌មានលំអិតស្តីពីការស្នើសុំធ្វើបត្យាប័នទណ្ឌិតដែលបានស្នើទៅកាន់ភាគីបញ្ជូន ឬ ព័ត៌មានលំអិតស្តីពីចំណាប់អារម្មណ៍របស់រដ្ឋណាមួយ ចំពោះការធ្វើបត្យាប័នទណ្ឌិត ឬ ព័ត៌មានលំអិតស្តីពីរដ្ឋណាមួយដែលភាគីបញ្ជូនយល់ឃើញថា អាចនឹងស្នើសុំធ្វើបត្យាប័នទណ្ឌិត ។

ង-	របាយការណ៍ស្តីពីការកែប្រែអត្តចរិត សុខភាព ឬស្ថានភាពរស់នៅរបស់ទណ្ឌិត ព័ត៌មានអំពីការប្រព្រឹត្តលើទណ្ឌិតនៅក្នុងដែនដីរបស់ភាគីបញ្ជូន និងអនុសាសន៍ទាក់ទងទៅនឹងការប្រព្រឹត្តដែលត្រូវអនុវត្តចំពោះទណ្ឌិតនាពេលអនាគតនៅក្នុងដែនដីនៃភាគីទទួល និង

ច- ព័ត៌មាននានាដទៃទៀតដែលស្នើសុំដោយភាគីទទួល ។

៤- ប្រសិនបើភាគីបញ្ជូនស្នើសុំ ភាគីទទួលត្រូវផ្តល់ជូននូវព័ត៌មានដូចខាងក្រោម មុនពេលបញ្ជូន :

ក- ឯកសារ ឬសេចក្តីថ្លែងការណ៍ដែលបញ្ជាក់ថាទណ្ឌិតអនុវត្តតាមលក្ខខណ្ឌនានាដែលមានចែងក្នុងមាត្រា ៤(ខ) ឬ ៤(គ) ។

ខ- សេចក្តីថ្លែងការណ៍មួយដែលចែងថា អំពើ ឬការគេចវេសមិនបានបំពេញ ដែលជាមូលហេតុនាំអោយមានការដាក់ទោស គឺជាធាតុផ្សំចាំបាច់នៃបទល្មើសព្រហ្មទណ្ឌ ស្របតាមច្បាប់របស់ភាគីទទួល ឬអាចជាធាតុផ្សំចាំបាច់នៃបទល្មើសព្រហ្មទណ្ឌ ប្រសិនបើបានប្រព្រឹត្តនៅក្នុងយុត្តាធិការនៃភាគីទទួល ឬសេចក្តីថ្លែងការណ៍ដែលភាគីទទួលលើកលែងលក្ខខណ្ឌនេះចោល ប្រសិនបើច្បាប់ក្នុងស្រុករបស់ខ្លួនអនុញ្ញាត ។

គ- សេចក្តីថ្លែងការណ៍រៀបរាប់ពីវិធី ដែលភាគីទទួលនឹងអនុវត្តទោសទៅលើទណ្ឌិត និង

ឃ- ព័ត៌មានបន្ថែមផ្សេងទៀត ។

៥- ប្រសិនបើមានការស្នើសុំ ភាគីណាមួយនៃភាគីទាំងពីរត្រូវផ្តល់ជូនគ្នាទៅវិញទៅមក តាមដែលអាចធ្វើទៅបាន នូវព័ត៌មានពាក់ព័ន្ធ ឯកសារ ឬសេចក្តីថ្លែងការណ៍នានា មុនពេលស្នើសុំអោយមានការបញ្ជូន ឬមុនពេលសម្រេចថា តើត្រូវយល់ព្រមអោយមានការបញ្ជូន ឬមិនត្រូវមានការបញ្ជូន ។

៦- ការប្រគល់ទណ្ឌិតដោយអាជ្ញាធរនៃភាគីបញ្ជូន ទៅអោយអាជ្ញាធរនៃភាគីទទួល ត្រូវធ្វើឡើងទៅតាមកាលបរិច្ឆេទ និងទីកន្លែងជាក់លាក់មួយ នៅក្នុងដែនដីនៃភាគីបញ្ជូន ស្របទៅតាមការព្រមព្រៀងគ្នាជាមុនរវាងភាគីទាំងពីរ ។

## មាត្រា ៦: ការយល់ព្រមរបស់ទណ្ឌិត

១- ភាគីបញ្ជូនត្រូវធានាថាទណ្ឌិតបានយល់ព្រមដោយស្ម័គ្រចិត្តចំពោះការបញ្ជូន និងបានយល់ដឹងយ៉ាងល្អិតល្អន់អំពីផលវិបាកផ្លូវច្បាប់ចំពោះការបញ្ជូននោះ ។ នីតិវិធីផ្តល់ការយល់ព្រម នឹងត្រូវកំណត់ដោយច្បាប់របស់ភាគីបញ្ជូន ។

២- មុនពេលបញ្ជូន ប្រសិនបើមានការស្នើសុំពីភាគីទទួល ភាគីបញ្ជូនត្រូវផ្តល់ឱកាសអោយភាគីទទួលចាត់តាំងមន្ត្រីរបស់ខ្លួន ធ្វើការផ្ទៀងផ្ទាត់ការយល់ព្រមរបស់ទណ្ឌិតចំពោះការបញ្ជូនត្រូវបានធ្វើឡើងដោយស្ម័គ្រចិត្ត និងបានយល់ដឹងយ៉ាងល្អិតល្អន់អំពីផលវិបាកផ្លូវច្បាប់ដែលអាចកើតមាន ស្របតាមមាត្រា ៤ (ច) ។

## មាត្រា ៧: ការរក្សាទុកយុត្តាធិការ

ភាគីបញ្ជូន រក្សាទុកយុត្តាធិការក្នុងការពិនិត្យឡើងវិញ ការសើរើ ការកែប្រែ ការលប់ចោល ការលើកលែង ការបន្ធូរបន្ថយ ឬការផ្លាស់ប្តូរ នូវពិរុទ្ធភាព និងទោសដែលតុលាការរបស់ខ្លួនបានសម្រេច ។

## មាត្រា ៨: ការបន្តអនុវត្តទោស

១- ភាគីទទួលត្រូវអនុវត្តទោសទៅលើទណ្ឌិត ដូចដែលភាគីបញ្ជូនបានសម្រេច ។

២- បន្ទាប់ពីមានការបញ្ជូន ការបន្តអនុវត្តទោសនឹងត្រូវគ្រប់គ្រងដោយច្បាប់ និងនីតិវិធីនៃភាគីទទួល ដោយពុំចាំបាច់គិតដល់លក្ខខណ្ឌដែលមានចែងក្នុងកថាខ័ណ្ឌទី ៣ នៃមាត្រា ៨ ឡើយ។ ក្នុងករណីដែលព្រះរាជាណាចក្រកម្ពុជា ជាភាគីទទួល ទណ្ឌិតមានសិទ្ធិទទួលនូវការលើកលែងទោស ឬការបន្ធូរបន្ថយទោស ដូចមានចែងក្នុងច្បាប់នៃព្រះរាជាណាចក្រកម្ពុជា ។ ប្រភេទ ឬរយៈពេលនៃទោសនោះ មិនត្រូវមានលក្ខណៈធ្ងន់ធ្ងរជាងកំរិតទោសដែលបានសម្រេចដោយភាគីបញ្ជូននោះទេ ។

៣- ប្រសិនបើប្រភេទ ឬរយៈពេលនៃការដាក់ទោស មិនស្របគ្នាទៅនឹងច្បាប់របស់ភាគីទទួល ភាគីទទួលអាចសម្របសម្រួលទោសនោះ ទៅតាមច្បាប់របស់ខ្លួនចំពោះបទល្មើសស្រដៀងគ្នា ។ ក្នុងករណីដែលត្រូវសម្របសម្រួលទោស អាជ្ញាធរមានសមត្ថកិច្ចរបស់ភាគីទទួល ត្រូវគោរពទៅតាមការរកឃើញនៃអង្គហេតុដែលបានមកពីគំនិត ពិរុទ្ធភាព សាលក្រម ឬទោស ដែលធ្វើឡើងដោយភាគីបញ្ជូន ។ ប្រភេទ ឬរយៈពេលនៃទោស ដែលអនុវត្តដោយសម្របសម្រួលនេះ មិនត្រូវមានលក្ខណៈធ្ងន់ធ្ងរជាងកំរិតទោសដែលបានកំណត់ដោយភាគីបញ្ជូនទេ ។

៤- ផ្អែកតាមច្បាប់របស់ភាគីទទួល ប្រសិនបើទណ្ឌិតជាអនិតិជន ភាគីទទួលអាចចាត់ទុកទណ្ឌិតនោះជាអនិតិជន ដោយមិនចាំបាច់គិតពីឋានៈរបស់ទណ្ឌិតនោះតាមច្បាប់របស់ភាគីបញ្ជូនទេ ។

៥- ភាគីទទួលត្រូវកែប្រែ ឬបញ្ចប់ ការអនុវត្តទោសភ្លាម បន្ទាប់ពីបានទទួលព័ត៌មានអំពីការសម្រេចណាមួយដោយភាគីបញ្ជូន ស្របតាមមាត្រា ៧ ។

៦- ភាគីទាំងពីរត្រូវជូនដំណឹងដល់ទណ្ឌិតជាលាយលក្ខណ៍អក្សរ អំពីសកម្មភាពណាមួយ ឬសេចក្តីសម្រេចនានាដែលធ្វើឡើងដោយភាគីបញ្ជូន ឬភាគីទទួល ដូចមានចែងចាប់ពីកថាខ័ណ្ឌទី ២ ដល់ កថាខ័ណ្ឌទី ៥ នៃមាត្រានេះ ។

## មាត្រា ៩: ព័ត៌មានអំពីការអនុវត្តទោស

ភាគីទទួលត្រូវផ្តល់ព័ត៌មាន ស្តីពីការអនុវត្តទោស ដល់ភាគីបញ្ជូនដូចតទៅ :

ក- ប្រសិនបើទណ្ឌិតត្រូវបានផ្តល់ការដោះលែងដោយមានលក្ខខណ្ឌ ។

ខ- នៅពេលដែលភាគីទទួលយល់ឃើញថា ការអនុវត្តទោសត្រូវបានបញ្ចប់ ។

គ- ប្រសិនបើទណ្ឌិតបានរត់គេចខ្លួនពីពន្ធនាគារ ឬទទួលមរណៈភាព មុនពេលបញ្ចប់ការអនុវត្តទោសជាស្ថាពរ ។

ឃ- ប្រសិនបើភាគីបញ្ជូនស្នើសុំរបាយការណ៍ ។

## មាត្រា ១០: ដំណើរឆ្លងកាត់នៃទណ្ឌិត

មាត្រានេះអនុវត្តក្នុងករណីដែលភាគីណាមួយបញ្ជូនទណ្ឌិតទៅកាន់ ឬចេញពីរដ្ឋទីបី ដែលភាគីទាំងពីរមានទំនាក់ទំនងក្នុងការផ្ទេរទណ្ឌិតជាមួយរដ្ឋនោះ។ ប្រសិនបើមានការបញ្ជូនទណ្ឌិត ហើយការបញ្ជូនឆ្លងកាត់ដែនដីរបស់ភាគីមួយផ្សេងទៀតជាការចាំបាច់ ភាគីម្ខាងទៀតត្រូវសហការជួយសំរួលការបញ្ជូនទណ្ឌិតនោះឆ្លងកាត់ដែនដីរបស់ខ្លួន ដោយស្របទៅតាមច្បាប់ក្នុងស្រុករបស់ខ្លួន ។ ភាគីដែលមានបំណងធ្វើការបញ្ជូនឆ្លងកាត់ ត្រូវផ្តល់ព័ត៌មានជាមុនដល់ភាគីម្ខាងទៀតអំពីការបញ្ជូននោះ ។

## មាត្រា ១១: ភាសា

សំណើសុំបញ្ជូន និងឯកសារដែលត្រូវអមមកជាមួយ ត្រូវមានភ្ជាប់នូវការបកប្រែជាភាសាផ្លូវការរបស់ភាគីទទួល ។

## មាត្រា ១២: ការចំណាយ

១- ការចំណាយសម្រាប់ការផ្ទេរទណ្ឌិត នឹងត្រូវសម្រេចដោយភាគីទាំងពីរ ផ្អែកតាមករណីជាក់ស្តែងនីមួយៗ ។

២- ការចំណាយសម្រាប់ការអនុវត្តទោសបន្ត បន្ទាប់ពីការបញ្ជូនទណ្ឌិតមកភាគីទទួល ជាបន្ទុករបស់ភាគីទទួល ។

៣- ទោះជាយ៉ាងណាក៏ដោយ ភាគីទទួលអាចតម្រូវអោយទណ្ឌិតសងការចំណាយទាំងស្រុង ឬមួយផ្នែកសម្រាប់ការបញ្ជូននេះ ។

## មាត្រា ១៣: ការពិគ្រោះយោបល់

អាជ្ញាធរកណ្តាលនៃភាគីទាំងពីរត្រូវពិគ្រោះយោបល់គ្នា ដើម្បីជំរុញការអនុវត្តកិច្ចព្រមព្រៀងនេះ អោយមានប្រសិទ្ធភាពខ្ពស់បំផុត និងលើកស្ទួយវិធានការអនុវត្តទាំងឡាយ ដើម្បីសម្រួលដល់ការអនុវត្តកិច្ចព្រមព្រៀងនេះ។

## មាត្រា ១៤: ការដោះស្រាយវិវាទ

១- ភាគីទាំងពីរត្រូវដោះស្រាយវិវាទដែលកើតចេញពីការបកស្រាយ ការប្រើប្រាស់ ឬ ការអនុវត្តកិច្ចព្រមព្រៀងនេះ តាមរយៈអាជ្ញាធរកណ្តាល ។

២- ប្រសិនបើអាជ្ញាធរកណ្តាល មិនមានលទ្ធភាពដោះស្រាយវិវាទ ដូចដែលមានចែងក្នុងកថាខ័ណ្ឌទី ១ នៃមាត្រា ១៤ ទេ ភាគីទាំងពីរត្រូវដោះស្រាយវិវាទនេះ តាមរយៈការចរចារផ្នែកការទូត ។

## មាត្រា ១៥: ដែនអនុវត្ត

កិច្ចព្រមព្រៀងនេះត្រូវអនុវត្តនៅក្នុងដែនដីនៃប្រទេសអូស្ត្រាលី និងដែនដីនៃព្រះរាជាណាចក្រកម្ពុជា ។

## មាត្រា ១៦: ការចូលជាធរមាន និងការបញ្ចប់

១- កិច្ចព្រមព្រៀងនេះត្រូវចូលជាធរមាន ៣០ ថ្ងៃ បន្ទាប់ពីភាគីទាំងពីរបានជូនដំណឹងគ្នាជាលាយលក្ខណ៍អក្សរថាខ្លួនបានបំពេញសព្វគ្រប់នូវលក្ខខណ្ឌទាំងឡាយ ដែលតម្រូវអោយកិច្ចព្រមព្រៀងនេះចូលជាធរមាន ។

២- កិច្ចព្រមព្រៀងនេះ ត្រូវអនុវត្តចំពោះរាល់សំណើសុំអោយមានការបញ្ជូន បន្ទាប់ពីកិច្ចព្រមព្រៀងនេះចូលជាធរមាន ទោះបីជាការផ្តន្ទាទោសត្រូវបានធ្វើឡើងមុនពេលកិច្ចព្រមព្រៀងនេះចូលជាធរមានក៏ដោយ ។

៣- ភាគីណាមួយក្នុងចំណោមភាគីទាំងពីរ អាចបញ្ចប់កិច្ចព្រមព្រៀងនេះនៅពេលណាក៏បាន ដោយជូនដំណឹងជាលាយលក្ខណ៍អក្សរទៅភាគីម្ខាងទៀត ។ ក្នុងករណីនេះ កិច្ចព្រមព្រៀងនឹងលែងមានសុពលភាពក្នុងរយៈពេល ៦ ខែ ក្រោយកាលបរិច្ឆេទនៃការទទួលបានការជូនដំណឹង ។

ដើម្បីជាសក្ខីភាពនៅក្នុងកិច្ចព្រមព្រៀងនេះ ហត្ថលេខីដែលត្រូវបានអនុញ្ញាតត្រឹមត្រូវអោយធ្វើជាតំណាងរដ្ឋាភិបាលនីមួយៗ បានចុះហត្ថលេខាលើកិច្ចព្រមព្រៀងនេះ ។

ធ្វើនៅ កង់បែរ៉ា នៅថ្ងៃទី ១៧ ខែ តុលា ឆ្នាំ ២០០៦ ចំនួនពីរច្បាប់ ជាភាសាអង់គ្លេស និងភាសាខ្មែរ ដែលអត្ថបទទាំងពីរនេះមានតម្លៃស្មើគ្នា ។

**តំណាងរដ្ឋាភិបាលនៃប្រទេសអូស្ត្រាលី** **តំណាងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា**

_______________________ _______________________